ក្រសួងអប់រំរដ្ឋ NSW



## Enrolment policy - Khmer

# គោលនយោបាយចុះឈ្មោះចូលរៀន

## ព័ត៌មានសម្រាប់ឪពុកម្តាយ

គោលនយោបាយចុះឈ្មោះចូលរៀននៃសិស្សក្នុងសាលារៀនរដ្ឋនៃរដ្ឋ NSW ត្រូវបានដាក់ឱ្យមានដំណើរការ ដើម្បីជួយដល់សាលារៀន បំពេញកាតព្វកិច្ចរបស់ពួកគេក្រោមច្បាប់ស្តីពីការអប់រំ ឆ្នាំ *1990* - ដើម្បីធានាថាសិស្សគ្រប់រូបមានកន្លែងរៀន នៅសាលារៀនក្នុងតំបន់ មូលដ្ឋានរបស់ពួកគេ។ គោលនយោបាយនេះក៏ប្រាស្រ័យទាក់ទងផងដែរជាមួយបុគ្គលិក និងសហគមន៍នូវដំណើរការចុះឈ្មោះចូលរៀនប្រកបដោយតម្លាភាព។

### ហេតុអ្វីបានជាគោលនយោបាយចុះឈ្មោះចូលរៀនត្រូវបានកែសម្រួល ឡើងវិញ?

សហគមន៍ជាច្រើនកំពុងផ្លាស់ប្តូរនៅទូទាំងរដ្ឋ។ ខ្លះកំពុងរីកចម្រើន ក្នុងអត្រាដែលមិនធ្លាប់ឃើញពីមុន។ សាលារៀនខ្លះដែលធ្លាប់មាន លទ្ធភាពទទួលយកការចុះឈ្មោះចូលរៀនសិស្សក្រៅតំបន់ ក៏លែងមានកន្លែងសម្រាប់នឹងធ្វើដូច្នេះ។

គោលនយោបាយដែលបានកែសម្រួលឡើងវិញ ត្រូវបានរចនាឡើង ក្នុងគោលបំណងគាំទ្រដល់សាលារៀន ដើម្បីគ្រប់គ្រងរាល់ការចុះឈ្មោះចូលរៀនលើកទឹកចិត្តឱ្យមានភាពមិនផ្លាស់ប្តូរជាងមុនក្នុងការធ្វើការសម្រេចចិត្ត និងដើម្បីប្រាកដថាជម្រើសចុះឈ្មោះចូលរៀនមាន ភាពច្បាស់លាស់សម្រាប់ឪពុកម្តាយ។

### តើមានការផ្លាស់ប្តូរអ្វីខ្លះ?

#### The enrolment cap

The enrolment cap គឺជាចំនួនសិស្សដែលអាចចុះឈ្មោះចូលរៀននៅសាលារៀន ដោយផ្អែកលើការដាក់ទីកន្លែងរៀនអចិន្ត្រៃយ៍របស់សាលា។ The enrolment cap ប្រាប់យើងថាតើសាលារៀនអាច ឬក៏មិនអាចមានសមត្ថភាពក្នុងការទទួលយកការចុះឈ្មោះសិស្សក្រៅតំបន់មូលដ្ឋាន។ វាមិនមែនជាគោលដៅ ឬដែនកំណត់លើចំនួននៃការចុះឈ្មោះក្នុងតំបន់មូលដ្ឋានដែលសាលារៀនអាច ទទួលយកបាននោះទេ។

សាលារៀននីមួយៗដែលមានតំបន់ទទួលយកសិស្សក្នុងតំបន់មូលដ្ឋាន នឹងមាន cap កំណត់ដោយក្រសួងចាប់ពី Term 4 2019។

នៅក្នុង the enrolment cap កន្លែងចុះឈ្មោះចូលរៀនមួយចំនួនត្រូវតែបានទុកដោយឡែកសម្រាប់ចំនួននៃសិស្សក្នុងតំបន់មូលដ្ឋាន ដែលនឹងត្រូវចុះឈ្មោះក្នុងឆ្នាំនោះ។ ចំនួនកន្លែងចុះឈ្មោះដែលត្រូវបានទុកដោយឡែក ហៅថា the buffer។ ដោយមូលហេតុនេះ សាលារៀនមួយនឹងមិនទទួលយកសិស្សក្រៅតំបន់មូលដ្ឋានឡើយ ពេលណាសាលារៀននោះចូលដល់ the buffer លើកលែងតែមានកាលៈទេសៈពិសេស។

#### ការពិនិត្យអាសយដ្ឋានរស់នៅ 100-ចំណុច

ឪពុកម្តាយដែលមានគម្រោងចុះឈ្មោះកូនរបស់ពួកគេនៅសាលារៀន ដែលនៅក្បែរ buffer ឬ cap ឬបានទៅដល់ buffer ឬ cap របស់ពួកគេ នឹងត្រូវបានស្នើសុំឱ្យបំពេញការពិនិត្យអាសយដ្ឋានរស់នៅ 100-ចំណុច ដើម្បីបញ្ជាក់ថាពួកគេរស់នៅក្នុងតំបន់ទទួលយកសិស្សក្នុងតំបន់មូលដ្ឋាន ដែលកំណត់ដោយសាលារៀន។ នេះមាន ន័យថា ឪពុកម្តាយត្រូវផ្តល់ឯកសារទាំងឡាយដើម្បីផ្ទៀងផ្ទាត់អាសយដ្ឋានបច្ចុប្បន្នរបស់កុមារ។

ដើម្បីថា សាលារៀនស្វែងរកព័ត៌មានពាក់ព័ន្ធនឹងការចុះឈ្មោះរបស់កុមារតែប៉ុណ្ណោះ បញ្ជីឯកសារដែលបានយល់ព្រម សម្រាប់ការត្រួតពិនិត្យអាស័យដ្ឋានលំនៅដ្ឋានមានផ្តល់ជូននៅសាលារៀន ឬ វ៉ិបសៃថ៍របស់ក្រសួងនៅត្រង់ https://education.nsw.gov.au/policy-library/policies/enrolment-of-students-in-nsw-government-schools.

#### លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសសម្រាប់ការចុះឈ្មោះសិស្សក្រៅតំបន់មូលដ្ឋាន

ការចុះសម្រាប់បងប្អូនបង្កើត ឥឡូវនេះគឺត្រូវបានផ្តល់អាទិភាពយ៉ាងច្បាស់។ (កន្លែងណាដែលអាចធ្វើទៅបាន) ហើយលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសសម្រាប់ការចុះឈ្មោះសិស្សក្រៅតំបន់មូលដ្ឋាន នឹងមិនរាប់បញ្ចូលសមត្ថភាពសិស្សការអនុវត្ត ឬសមិទ្ធិផលឡើយ។

## តើអ្វីខ្លះដែលមិនបានផ្លាស់ប្តូរ?

សាលារៀននឹងបន្តចុះឈ្មោះសិស្សដែលរស់នៅក្នុងតំបន់ទទួលយកសិស្សក្នុងតំបន់មូលដ្ឋានរបស់ពួកគេ ដោយមិនគិតពីស្ថានភាព cap របស់សាលារៀនឡើយ។

មិនមានការផ្លាស់ប្តូរចំពោះសិទ្ធិចុះឈ្មោះចូលរៀន របស់បងប្អូនបង្កើតនៃសិស្សក្រៅតំបន់មូលដ្ឋានទេ។ នៅតាមសាលារៀនដែលមានកន្លែងទំនេរពាក្យសុំចុះឈ្មោះចូលរៀននីមួយៗ ត្រូវបានពិចារណាលើគុណសម្បត្តិរបស់ខ្លួន រួមមានប្រសិនបើបច្ចុប្បន្នមានបងប្អូនបង្កើតចូលរៀននៅសាលានោះ។ ប្រសិនបើសាលារៀនមានសមត្ថភាពទាប នោះពាក្យសុំចូលរៀនពីសិស្សក្រៅតំបន់សម្រាប់បងប្អូនបង្កើតរបស់ សិស្សបច្ចុប្បន្ន នឹងត្រូវបានផ្តល់អាទិភាពសម្រាប់ការចុះឈ្មោះចូល រៀន។

សាលារៀននឹងបន្តផ្តល់ការគាំទ្រ និងដំបូន្មានដល់ក្រុមគ្រួសារក្នុងអំឡុងដំណើរការចុះឈ្មោះ  រួមមានការវាយតម្លៃអំពីកាលៈទេសៈ ពិសេសនិងគួរឱ្យទាក់ទាញអារម្មណ៍ ជាពិសេសសម្រាប់សិស្សងាយរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ។

សាលារៀនក៏នឹងបន្តអនុវត្តគោលនយោបាយដែលមិនលំអៀងនិងជាប់លាប់ដែរ ដោយប្រើដំណើរការប្រកបដោយតម្លាភាព និងភាពទទួលខុសត្រូវ នៅពេលធ្វើការសម្រេចចិត្តអំពីពាក្យសុំចុះឈ្មោះ ចូលរៀន។ ឪពុកម្តាយមានសិទ្ធិប្តឹងតវ៉ាដើម្បីកំណត់ ថាតើដំណើរការដែលបានបញ្ជាក់ ត្រូវបានអនុវត្តតាមនីតិវិធីត្រឹមត្រូវ ឬក៏អត់។

## ប៉ុន្តែ តើការផ្លាស់ប្តូរមានន័យអ្វីសម្រាប់ខ្ញុំ?

### ចុះប្រសិនបើកូនរបស់ខ្ញុំបានចុះឈ្មោះរួចហើយ ប៉ុន្តែយើងមិនរស់នៅក្នុងតំបន់ទទួលយកសិស្សរបស់សាលារៀននោះ?

កូនរបស់អ្នកនឹងនៅតែចុះឈ្មោះចូលរៀននៅសាលានោះដដែល ដ្បិតអីគោលនយោបាយដែលបានកែសម្រួលឡើងវិញនេះ មិនប៉ះពាល់ដល់សិស្សដែលបានចុះឈ្មោះចូលរៀនរួចហើយ នៅសាលារៀនរដ្ឋនៃរដ្ឋ NSW ទេ។

### យើងស្ថិតនៅក្នុងតំបន់នៅពេលដែលកូនរបស់ខ្ញុំបានចុះឈ្មោះចូលរៀននៅសាលានោះ។ ចាប់តាំងពីពេលនោះមកក្រសួងបានផ្លាស់ប្តូរព្រំប្រទល់របស់សាលារៀន ហើយទីលំនៅរបស់យើងឥឡូវនេះនៅក្រៅតំបន់។ ខ្ញុំមានកូនៗផ្សេងទៀត ហើយខ្ញុំចង់ឱ្យពួកគេទៅសាលារៀនតែមួយ។<br>តើខ្ញុំមានជម្រើសអ្វីខ្លះ?

នៅពេលខ្លះ វាជាការចាំបាច់សម្រាប់ក្រសួងដើម្បីការធ្វើការកែតម្រូវ ទៅលើតំបន់ទទួលសិស្សចុះឈ្មោះចូលរៀនក្នុងតំបន់មូលដ្ឋានរបស់សាលា។ នេះអាចមានន័យថា គ្រួសារដែលមានកូនម្នាក់ ឬកូនច្រើន ដែលបានចុះឈ្មោះរួចហើយ ក្រោយមកក៏នៅក្រៅតំបន់ទទួលសិស្សចុះឈ្មោះចូលរៀនក្នុងតំបន់មូលដ្ឋាន។ នៅពេលរឿងនេះកើត ឡើង ក្រុមគ្រួសារនៅតែអាចចុះឈ្មោះចូលរៀនសម្រាប់បងប្អូនបង្កើត ជាមួយគ្នានៅសាលានោះ ដោយមិនគិតពីថាតើសាលានេះលើសពី buffer ឬ cap។

### ខ្ញុំមានកូនចុះឈ្មោះរួចហើយ ថាជាសិស្សនៅក្រៅតំបន់នៅក្នុងសាលារៀនរដ្ឋនៃរដ្ឋ NSW តើខ្ញុំអាចចុះឈ្មោះកូនផ្សេងទៀតរបស់ខ្ញុំនៅសាលារៀននោះបានដែរឬទេ?

នេះគឺអាស្រ័យលើសមត្ថភាពរបស់សាលារៀននោះ៖

- ប្រសិនបើសាលារៀន**មិននៅក្បែរ buffer របស់ខ្លួនទេ** នោះបងប្អូនបង្កើតគួរតែអាចចុះឈ្មោះចូលរៀននៅសាលានោះបាន។ តាមពិត បងប្អូនបង្កើតនៃសិស្សដែលបានចុះឈ្មោះបច្ចុប្បន្ន នឹងត្រូវបានផ្តល់អាទិភាព ប្រសិនបើអាចធ្វើទៅបានលើពាក្យសុំចុះឈ្មោះសិស្សក្រៅតំបន់មូលដ្ឋានផ្សេងទៀត ។
- ប្រសិនបើសាលារៀន**នៅក្បែរ buffer របស់ខ្លួន** នោះសាលារៀននឹងបង្កើតក្រុមចុះឈ្មោះសិស្សក្រៅតំបន់មូលដ្ឋានមួយ។ ក្រុមនេះពិចារណាលើពាក្យសុំចុះឈ្មោះសិស្សក្រៅតំបន់មូលដ្ឋាន នៅពេលចំនួននៃពាក្យសុំចុះឈ្មោះសិស្សក្រៅតំបន់មូលដ្ឋាន ទទួលបានលើសចំនួនកន្លែងដែលមាននៅក្រោម buffer។ ជាថ្មីម្តងទៀត នៅក្នុងឧទាហរណ៍ នេះបងប្អូនបង្កើតនៃសិស្សដែលបានចុះឈ្មោះក្នុងពេលបច្ចុប្បន្ន នឹងត្រូវបានផ្តល់អាទិភាព ប្រសិនបើអាចធ្វើទៅបានលើពាក្យសុំចុះឈ្មោះសិស្សក្រៅតំបន់ មូលដ្ឋានផ្សេងទៀត។
- ប្រសិនបើសាលារៀនពេញសមត្ថភាព ពោលគឺពេញគ្រប់ចំនួន ពួកគេនឹងមិនទទួលយកពាក្យសុំចុះឈ្មោះសិស្សក្រៅតំបន់មូលដ្ឋានទេលើកលែងតែមានកាលៈទេសៈពិសេស។

### បានទទួលយកការផ្តល់ជូនកន្លែងសម្រាប់កូនរបស់ខ្ញុំរួចហើយ ដើម្បីចូលរៀននៅឆ្នាំ 2020 ដែលមិនមែនជាសាលាក្នុងតំបន់មូល ដ្ឋានរបស់ខ្ញុំ។ តើមានអ្វីកើតឡើងឥឡូវនេះ?

ការចុះឈ្មោះនឹងបន្ត។ ការចុះឈ្មោះសិស្សក្រៅតំបន់មូលដ្ឋានដែល បានទទួលយកមុន  Term 4 2019 សម្រាប់សិស្សដែលចាប់ផ្តើមក្នុងឆ្នាំ 2020 មិនគួររងប៉ះពាល់ទេ។

### តើមានលក្ខណៈវិនិច្ឆ័យអ្វីខ្លះសម្រាប់ការចុះឈ្មោះចូលរៀននៅសាលារៀនដែលមិនមែនជាសាលារៀនក្នុងតំបន់មូលដ្ឋានរបស់ខ្ញុំ?

សាលារៀនដែលអាចទទួលយកពាក្យសុំចុះឈ្មោះសិស្សក្រៅតំបន់ មូលដ្ឋាន បង្កើតជាក្រុមជ្រើសរើសការចុះឈ្មោះសិស្សក្រៅតំបន់មូលដ្ឋានមួយ ប្រសិនបើមានតម្រូវការលើសចំនួនកន្លែងនៅក្រោម buffer របស់សាលារៀន។

សាលារៀនត្រូវបានតម្រូវឱ្យមាន លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស សម្រាប់ផ្តល់ជូនសហគមន៍សាលារៀន។

### កាលៈទេសៈរបស់ខ្ញុំគឺពិបាក ហើយខ្ញុំគិតថាសាលារៀននេះល្អបំផុតសម្រាប់កូនរបស់ខ្ញុំ។ យើងរស់នៅខាងក្រៅតំបន់ទទួលយកសិស្សក្នុងតំបន់មូលដ្ឋានរបស់សាលារៀន។ តើខ្ញុំគួរធ្វើអ្វី?

យើងយល់ដឹងថាមិនមែនស្ថានភាពរបស់មនុស្សគ្រប់រូបដូចគ្នាទេ ហើយមានករណីកើតឡើងដែលជាកាលៈទេសៈពិសេសនិងគួរឱ្យ ទាក់ទាញអារម្មណ៍ដែលចាំបាច់ត្រូវគិតពិចារណា។

ប្រសិនបើមានករណីនេះ អ្នកគួរតែនិយាយជាមួយនាយកសាលាក្នុងតំបន់មូលដ្ឋានរបស់អ្នក។

## ទំនាក់ទំនង

សម្រាប់ទំនាក់ទំនងការសាកសួរព័ត៌មានទូទៅ៖ 1300 679 332
ឬអ៊ីម៉េល៖ DoEinfo@det.nsw.edu.au

សម្រាប់ការសាកសួរអំពីការចុះឈ្មោះ សូមនិយាយទៅកាន់សាលា រៀនក្នុងតំបន់មូលដ្ឋានរបស់អ្នក។ ស្វែងរកព័ត៌មានទំនាក់ទំនងលម្អិតរបស់សាលា នៅតាមវ៉ិបសៃថ៍៖ https://education.nsw.gov.au/public-schools/going-to-a-public-school/finding-a-public-school

## សេវាកម្មអ្នកបកប្រែភាតាមទូរស័ព្ទ

ប្រសិនបើអ្នកត្រូវការអ្នកបកប្រែភាសា ដើម្បីជួយអ្នកទាក់ទងមក សាលារៀន សូមទូរស័ព្ទទៅសេវាកម្មអ្នកបកប្រែភាសាតាមទូរស័ព្ទ លេខ 13 14 50 ហើយស្នើសុំអ្នកបកប្រែជាភាសារបស់អ្នក។ ប្រាប់ប្រតិបត្តិករនូវលេខទូរស័ព្ទដែលអ្នកចង់ហៅ ហើយប្រតិបត្តិករនឹងរៀបចំអ្នកបកប្រែភាសាតាមទូរស័ព្ទជូនអ្នកសម្រាប់ការសន្ទនា។ អ្នកនឹងមិនត្រូវគេគិតថ្លៃសម្រាប់សេវាកម្មនេះទេ។